01309621

002/19-09-2007-ECCC/TC
**E1/425**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 07 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៤០៦

រៀបចំដោយ៖កញ្ញា **ជា ស៊ីវហ៊ង** និងលោក Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ , ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖កញ្ញា ជា ស៊ីវហ៊ង និងលោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde D' ESTMAEL , កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស និង លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD , លោក ពេជ អង្គ, លោកស្រី ទី ស្រ៊ុនណា និង លោក វ៉ែន ពៅ |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ ប្រាក់ ខន (2-TCW-931) និង ម៉ក់ ស៊ីធីម (2 TCW 808) |
| មេធាវីប្រឹក្សា៖ លោក ម៉ម រិទ្ធា, លោក មឿន សុវណ្ណ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក អុច អរុណ, កញ្ញា សូ សុធាវី កញ្ញា សុក សុភ័គមណីកា, លោក វ៉ាត សុម៉ៅ, កញ្ញា យស សេរីរ័ត្ន, លោកស្រី ពេជ ចរិយា, កញ្ញា សួន ដារ៉ាវស្ដី |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៥.៥៩ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.០៦ | បញ្ចប់ម៉ោង៖ ១០.២៨ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.១៨ | បញ្ចប់ម៉ោង៖ ១៤.៣៨ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ម៉ោង ១៧នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៤ | ០៩.០៦ |
| ការតាំងសំណួរទៅកាន់សាក្សី ប្រាក់ ខន (2-TCW-931) | មេធាវីការពារក្ដី នួន ជា<br><br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៧<br>១១.១៥<br>០៩.៤៣<br>១០.៣១ | ០៩.៣៤<br>១១.៣១<br>១០.០១<br>១១.១២ |
| សំណើរបស់មេធាវីការពារក្ដី នួន ជា សុំប្រើប្រាស់ចម្លើយសារភាពរបស់ ឆុន ក្នុងការតាំងសំណួរទៅសាក្សី 2-TCW-931 | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.៣៤<br>០៩.៣៦<br>០៩.៣៩ | ០៩.៣៦<br>០៩.៣៩<br>០៩.៤០ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្ដី នួន ជា | ០៩.៤០ | ០៩.៤៣ |
| ការឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្ដី នួន ជា សុំពន្យារពេល ៤ សប្ដាហ៍ដើម្បីពិនិត្យទៅលើបញ្ជីឈ្មោះអ្នកទោសនៅ ស- ២១ ដែលបានធ្វើដោយសហចៅក្រមស៊ើបអង្កេត | អង្គជំនុំជម្រះ | ១៣.៣០ | ១៣.៣២ |
| | សហព្រះរាជអាជ្ញា | ១៣.៣២ | ១៣.៤៦ |
| | | ១៤.១១ | ១៤.១៤ |
| | សហមេធាវីនាំមុខ | ១៣.៤៦ | ១៣.៥០ |
| | មេធាវីការពារក្ដី ខៀវ សំផន | ១៣.៥១ | ១៣.៥៨ |
| | | ១៤.១៦ | ១៤.១៧ |
| | មេធាវីការពារក្ដី នួន ជា | ១៣.៥៨ | ១៤.១១ |
| | | ១៤.១៥ | ១៤.១៦ |
| ការតាំងសំណួរទៅកាន់សាក្សី ម៉ក់ ស៊ីធឹម (2-TCW-808) | អង្គជំនុំជម្រះ | ១៤.៤១ | ១៤.៥១ |
| | សហព្រះរាជអាជ្ញា | ១៤.៥១ | ១៥.៥៧ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់សាក្សី ប្រាក់ ខន (2-TCW-931)**

មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅ សាក្សី ប្រាក់ ខន (2-TCW-931) ។

**សំណើរបស់មេធាវីការពារក្ដី នួន ជា សុំប្រើប្រាស់ចម្លើយសារភាពរបស់ ឆុន ក្នុងការតាំងសំណួរទៅសាក្សី 2-TCW-931**

មេធាវីការពារក្ដី នួន ជា បានលើកឡើងថាចម្លើយសារភាពរបស់អ្នកទោសនៅ ស-២១ ឈ្មោះ ឆុន

គឺមិនមែនទទួលបាលដោយអំពើទារុណកម្មនោះទេ ហេតុដូចនេះមេធាវីការពារក្តីគួរអាចប្រើប្រាស់បានក្នុងការតាំងសំណួរទៅកាន់សាក្សីរូបនេះ។ ការវាយដំដែលបានរៀបរាប់ដោយសាក្សីប្រហែលជាអាចរាប់បញ្ចូលថាជាអំពើអមនុស្សធម៌ និងបន្ទាបបន្ថោក ប៉ុន្តែនេះមិនច្បាស់លាស់ដែរ។

សហព្រះរាជអាជ្ញាបានលើកឡើងថា មានការសន្មតដែលថាមានការប្រព្រឹត្តអំពើទារុណកម្មដើម្បីទទួលបានចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរ ស-២១ យោងទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ បន្ថែមពីលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា ការប្រព្រឹត្តលើអ្នកទោសទោះបីជាមុនពេលដែលពួកគេត្រូវបានសួរចម្លើយក៏ដោយ គឺជាអំពើទារុណកម្ម ហើយអំពើទារុណកម្មគឺមិនកំណត់ត្រឹមតែទារុណកម្មលើរូបរាងកាយនោះទេ តែក៏រាប់បញ្ចូលអំពើទារុណកម្មលើផ្លូវចិត្តដែលពួកគេទទួលរងដោយសារតែស្ថានភាពនៃការឃុំឃាំងខ្លួនផងដែរ។

សហមេធាវីនាំមុខយល់ស្របទៅនឹងអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។ សហមេធាវីនាំមុខបានលើកឡើងថាមេធាវីការពារក្តី នួន ជា មិនបានបង្ហាញថាអំពើទារុណកម្មមិនត្រូវបានប្រព្រឹត្តដើម្បីទទួលបានចម្លើយសារភាពរបស់ អុន នោះទេ។ សហមេធាវីនាំមុខបានអះអាងថា យោងតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ អ្នកទោសបានទទួលរងនូវបរិយាកាសភ័យខ្លាចដែលប៉ះពាល់ដល់ចម្លើយសារភាពរបស់ពួកគេ។

មេធាវីការពារក្តី នួន ជា បានឆ្លើយតបថាលក្ខណ្ឌវិនិច្ឆ័យសម្រាប់និយមន័យនៃពាក្យ ទារុណកម្ម ដែលមានចែងនៅក្នុងអនុសញ្ញា គឺមិនត្រូវបានបំពេញនៅក្នុងករណីនេះនៅឡើយ (នៅក្នុងការប្រព្រឹត្តលើ អុន)។ មេធាវីការពារក្តីបានលើកឡើងថា និយមន័យនៃ ទារុណកម្ម ដែលត្រូវបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ មានលក្ខណៈទូលំទូលាយពេក និងលើសពីព្រំដែននៃការកំណត់និយមន័យដែលមានចែងនៅក្នុងអនុសញ្ញា។

អង្គជំនុំជម្រះបានសម្រេចថាភាគីត្រូវបានហាមឃាត់មិនអោយប្រើប្រាស់ចម្លើយសារភាពរបស់ អុន ក្នុងការតាំងសំណួរទៅកាន់សាក្សីនេះទេ។ ប្រសិនបើ បន្ទាប់ពីការពិនិត្យលើសំណើរបស់ភាគី និងទៅលើឯកសារនោះ ហើយអង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពនោះ អង្គជំនុំជម្រះនឹងកោះហៅសាក្សីនោះមកវិញនៅពេលសមរម្យណាមួយ។

<u>ការឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា សុំពន្យារ ពេល ៤ សប្តាហ៍ដើម្បីពិនិត្យទៅលើបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស- ២១ ដែលបានធ្វើដោយសហចៅក្រមស៊ើបអង្កេត</u>

សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា សុំពន្យារពេលសវនាការរយៈពេល ៤ សប្តាហ៍។ សហព្រះរាជអាជ្ញាបានលើកឡើងថាឯកសារដែលបានប្រើប្រាស់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើជាមូលដ្ឋានសម្រាប់បញ្ជីអ្នកទោស ស-២១ ដែលបានកែសម្រួលនោះគឺអាចរកបានតាំងពីយូរមកហើយ ដោយមាននៅក្នុងសំណុំរឿង និងមាននៅ DC-CAM អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ សហព្រះរាជអាជ្ញាបានទទួលស្គាល់នូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ប៉ុន្តែក៏បានលើកឡើងផងដែរថាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងផលប្រយោជន៍សាធារណៈក្នុងការបន្តកិច្ចដំណើរការនីតិវិធីឱ្យទៅមុខ ដើម្បីឈានដល់ការបញ្ចប់កិច្ចដំណើរការនីតិវិធី គឺមិនគួរត្រូវបានអើពើនោះទេ។

ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានស្នើសុំថា ក្នុងចំណោមសាក្សីទាំង៣ ដែលត្រូវមកផ្តល់សក្ខីកម្មសម្រាប់អង្គហេតុ ស-២១ សាក្សី 2-TCW-906 គួរតែមកផ្តល់សក្ខីកម្មតាមកាលវិភាគដែលបានកំណត់ ដោយសារតែសាក្សីនេះមិនជាប់ពាក់ព័ន្ធទៅនឹងបញ្ជីថ្មីនោះទេ ប៉ុន្តែគាត់នឹងផ្តល់សក្ខីកម្មលើព្រឹត្តិការណ៍ទូទៅ ជាពិសេសគឺនៅ ជើងឯក។ សហព្រះរាជអាជ្ញាបានស្នើថា សាក្សីដែលមានភាពស្មុគ្រស្មាញតិចតួចដែលត្រូវមកផ្តល់សក្ខីកម្មក្នុងអង្គហេតុ ការបោសសម្អាតផ្ទៃក្នុង (2-TCCP-236, TCW-2-917, TCW-2-812 និង TCW-2-976) អាចនឹងត្រូវបានផ្លាស់ប្តូរឱ្យមកផ្តល់សក្ខីកម្មមុន ដើម្បីអនុញ្ញាតអោយមេធាវីការពារក្តីទាំងពីរក្រុមមានពេលវេលារៀបចំសម្រាប់សាក្សី ២ នាក់ទៀតដែលនៅសេសសល់សម្រាប់អង្គហេតុមន្ទីរ ស-២១ គឺ 2-TCW-816 និង 2-TCW-916។

សហមេធាវីនាំមុខបានលើកឡើងថា ពួកគាត់នឹងពឹងផ្អែកទៅលើការសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហានេះថាតើគួរ ឬ មិនគួរពន្យាពេលកិច្ចដំណើរការនីតិវិធីសវនាការ និងរយៈពេលនៃការផ្អាកសវនាការនេះប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត។ សហមេធាវីនាំមុខបានធ្វើការកត់សម្គាល់អំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការជំនុំជម្រះឆាប់រហ័ស ប៉ុន្តែក៏កត់សម្គាល់ផងដែរថាផលប្រយោជន៍នេះ មិនគួរជាការចំណាយនៃសិទ្ធិរបស់ជនជាប់ចោទនោះទេ។

មេធាវីការពារក្តី ខៀវ សំផន គាំទ្រទៅលើសំណើសុំផ្អាកសវនាការរយៈពេល ៤ សប្តាហ៍។ មេធាវីកាពារក្តីបានលើកឡើងថាវាមានវិសមភាពពាក់ព័ន្ធនឹងផ្នែកធនធានមនុស្សសម្រាប់ក្រុមមេធាវីការពារក្តី បើប្រៀបទៅនឹងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសចំពោះសមត្ថភាពភាគីក្នុងការរៀបចំឯកសារដើម្បីការតាំងសំណួរទៅកាន់សាក្សី។ ដោយហេតុថា មេធាវីការពារក្តីត្រូវអង្គុយនៅក្នុងសវនាការជារៀងរាល់ថ្ងៃដើម្បីធ្វើការតាំងសំណួរទៅកាន់សាក្សី ហើយថាសំណើរបស់សហព្រះរាជអាជ្ញាសុំពន្លឿនការស្តាប់សក្ខីកម្មរបស់សាក្សីសម្រាប់អង្គហេតុ ការបោស

សម្អាតផ្ទៃក្នុង នោះគឺមិនជួយអ្វីដល់ខាងមេធាវីការពារក្តីនោះទេ។ ប្រសិនបើអង្គជំនុំជម្រះមិនព្រមពន្យាពេលកិច្ចនីតិវិធីសវនាការនោះទេ អង្គជំនុំជម្រះគួរតែអនុញ្ញាតអោយខាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតាំងសំណួរមុនទៅកាន់សាក្សីដែលនៅសេសសល់ ហើយមេធាវីការពារក្តីនឹងតាំងសំណួរបន្ទាប់ពីការឈប់សម្រាកតុលាការ។

មេធាវីការពារក្តី នួន ជា បានយល់ស្របជាមួយនឹងមេធាវីការពារក្តី ខៀវ សំផន ដែលថាមេធាវីការពារក្តីមិនមានពេលវេលាគ្រប់គ្រាន់ និងមិនមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការដោះស្រាយជាមួយនឹងព័ត៌មានថ្មី និងឯកសារដែលបានមកពីបញ្ជីដែលបានកែសម្រួលនោះទេ។ មេធាវីការពារក្តីបានលើកឡើងថារយៈពេល៤សប្តាហ៍ក្នុងការផ្អាកកិច្ចនីតិវិធីសវនាការវាជារឿងសមហេតុផលមួយនៅពេលដែលផ្អែកទៅលើទស្សនៈមួយដែលថារយៈពេលនៃការជំនុំជម្រះនេះ មានរយៈពេល ៨ ឆ្នាំ និង ៧ ខែ មកហើយ ចាប់តាំងពីការចាប់ខ្លួនលោក នួន ជា។

មិនមានភាគីណាជំទាស់ទៅនឹងការទទួលយកឯកសារថ្មីដែលជាមូលដ្ឋានសម្រាប់ធ្វើបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ដែលបានកែសម្រួលនោះទេ។ ភាគីទាំងអស់បានគាំទ្រការទទួលយកឯកសារនេះជាភ័ស្តុតាង។

អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើបញ្ហានេះក្នុងពេលសមស្របខាងមុខ។

## Reclassified

| TC No. | OCIJ No. | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/8368 | | 00007445-00007513; 00182945-00182974, 00225379-0022541; 00278744-00278776 | Statistique list of Santibal S-21 | P | 00007458; 00007465 | 00225388; 00225391 | 00278752;00278756 |
| E3/7464 | | 00356192-00356276; 00355961-00356075; 00356076-00356191 | Transcript of Proceedings - "Duch" Trial - 22 July 2009 | P | / | 00356036-00356038 | 00356151-00356153 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/9431 | | 00181395-00181448; 00198028-00198081; 00181449-00181502 | Annex 1: Report of Crime Scene Reenactment at TUOL Sleng on 27 February 2008 | P | 00181396 | 00198029 | 00181450 |
| E3/3680 | | 00174575-00174578; 00225270-00225270 00771351-00771354; 00267875-00267875 00766969-00766971 | Annex 69: 618bbkkh Colour copy Excerpt of Confession of Eng Meng Heang alias Chhon | P | / | / | / |
| E3/4280 | | 00294991-00294992 | S-21 Confession of ENG Meng Heang alias CHHON (summary of confessions) | P | / | / | / |
| E3/8386 | | 00002637-00002640; 00521631-00521634; 00532733-00532736 | S-21 (K-8): Circulations | P | 00002637 | 00521631 | 00532733 |
| E3/7315 | | S 01137156-01137173; S 00013209-00013216 | "SWB, Far Eastern Relations, October 25, 1978" | P | S01137156 | S00013209 | / |
| E3/5800 | | 00342749-00342828; 00341955-00342058; 00342059-00342169 | Transcript of Proceedings - "Duch" Trial - 16 June 2009 | P | / | 00342034-00342035 | 00342145 |
| E3/7673 | | 00163709-00163713; 00401868-00401874; 00305209-00305215 | [Corrected 1] Written Record of Interview of Mak Sithim | P | 00163711; 00163713 | 00401871; 00401872 | 00305212; 00705214 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/833 | | 0007761-00078056; 00282468-00282547 | [Partial T.] S-21 Livre de Mam Nai alias Chan | P | 0077729 | / | 00282536 |
| E3/79 | | 00146593-00146612; 00146593-00146612; 00164583-00164607 | Written Record of Interview of Prak Khan | P | 00146594 | 00161554 | 001647587 |
| E3/1549 | | 00174392-00174434; 00769683-00769715; 00965737-00965779 | 555bbkkh Colour copy Excerpt of Confession of Eng Meng Heang alias Chhon | P | / | / | / |
| E402 | | 01239059-01239075; 01236719-01236730 | Nuon Chea's urgent request for additional time to prepare for the examination of the remaining s-21 witnesses in order to safeguard his fundamental fair trial rights | P | / | 01236730 | / |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៣)
- សម្រេចមិនអនុញ្ញាតិឱ្យភាគីប្រើប្រាស់ចម្លើយសារភាពរបស់ ឆុន ក្នុងការតាំងសំណួរទៅកាន់សាក្សី (១០.១២)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦។ (១៦.២៥)

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.០២ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីវ[illegible] Roger PHILLIPS